គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

G B MICROFINANCE INSTITUTION PLC.



# របាយការណ៍ប្រចាំឆ្នាំ២០២១


អគារ ចេ-៣៧ ផ្លូវលំ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+៨៥៥)២៣ ៩៧៧ ៧៧៨ / ៩៩ ៥៧០ ៥៥៥

info@gbmfi.com.kh

www.linkedin.com/g-b-microfinance-institution-plc-1893ba1b6

www.gbmfi.com.kh

www.facebook.com/gbmicrofinance

# មាតិកា


១ សារតាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ..... ០១
២ សាររបស់ប្រធានក្រុមប្រឹក្សាភិបាល ..... ០២
៣ សាររបស់នាយកប្រតិបត្តិ ..... ០៣
៤ ទស្សនវិស័យរបស់គ្រឹះស្ថាន ..... ០៤
៥ បេសកកម្មរបស់គ្រឹះស្ថាន ..... ០៥
៦ តម្លៃស្នូលរបស់គ្រឹះស្ថាន ..... ០៦
៧ រចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ..... ០៧
៨ ក្រុមប្រឹក្សាភិបាល ..... ០៨
៩ គណៈគ្រប់គ្រង ..... ១២
១០ ផលិតផល និងសេវាកម្ម ..... ១៩
១១ ច្បាប់ និងបទប្បញ្ញត្តិនានា ..... ២១
១២ សកម្មភាពសង្គម និងសប្បុរសធម៌ ..... ២៣

ផ្នែករបាយការណ៍សវនកម្មស្ដីអំពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២១៖

១៣ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ..... ២៥
១៤ របាយការណ៍របស់សវនករឯករាជ្យ ..... ២៨
១៥ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ..... ៣៣
១៦ របាយការណ៍លទ្ធផលពេញលេញ ..... ៣៤
១៧ របាយការណ៍បំរែបំរួលមូលធន ..... ៣៥
១៨ របាយការណ៍បំរែបំរួលសាច់ប្រាក់ ..... ៣៦
១៩ សេចក្ដីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល ..... ៣៨
២០ មូលនិធិផ្ទាល់សុទ្ធ ..... ៣៩
២១ អនុបាតសាច់ប្រាក់ងាយស្រួល ..... ៤០
២២ ចំណាត់ថ្នាក់ឥណទាននិងសំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ និងបាត់បង់ ..... ៤១
២៣ ការគណនាស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ ..... ៤២

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

## ការិយាល័យកណ្តាលៈ ទីក្រុងកោះពេជ្រ រាជធានីភ្នំពេញ



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ត្រូវបានបង្កើតឡើងដោយ លោក តាំង គួងហាវ និង លោកស្រី HSU, CHIA-CHIA ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ០០០៨៣៩០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ចេញដោយក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ត្រូវបានផ្តល់អាជ្ញាបណ្ណ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយធនាគារជាតិ នៃ កម្ពុជា លេខ ម.ហ ៩២ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានក្លាយជាសមាជិកនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(CMA) ដែលមានវិញ្ញាបនបត្រសមាជិក លេខ ១២២/ ២០ស៊ីអឹមអេ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០២០។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក សូមសាទរចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដែលមានប្រាក់ចំណូលពីកម្រិតទាបឡើងទៅនៅក្នុងប្រទេស និងគាំទ្រដល់ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣-២០៣០។

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

## លោក ឧកញ៉ា តាំង គួងបាវ
ប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក



តាមការព្យាករណ៍របស់ធនាគារពិភពលោកបង្ហាញថា ដំណាក់កាលវីរុសកូវីដ១៩កំពុងរាតត្បាតជាសកល សេដ្ឋកិច្ចកម្ពុជាអាចរក្សាកំណើន ដើបឡើងវិញប្រមាណ៤% នៅឆ្នាំ២០២១ បន្ទាប់ពីការថយចុះចំនួន៣.១% នៅឆ្នាំ២០២០។ ការងើបឡើងវិញនេះគឺដោយសារតែការវិលត្រឡប់នៃតម្រូវការសកល។

ដោយឡែក លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសនៅមានលំនឹង ដែលបានជួយគាំទ្រដល់វិស័យអចលនទ្រព្យ និងសំណង់ និងពាណិជ្ជកម្មក្រៅប្រទេសជាដើម អំឡុងពេលផលប៉ះពាល់ពីវីរុសជំងឺកូវីដ១៩នេះ។

ក្នុងដំណាក់កាលទទួលរងផលប៉ះពាល់ពីវីរុសជំងឺកូវីដ១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជានេះដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានចូលរួមផ្តល់ដំណោះស្រាយហិរញ្ញវត្ថុ ចំពោះអតិថិជនដែលទទួលរងផលប៉ះពាល់ជំងឺកូវីដ១៩ តាមរយៈការផ្តល់ឥណទានរៀបចំឡើងវិញ និងអនុគ្រោះសោហ៊ុយផ្សេងៗ។

យើងនៅតែបន្តផ្តល់ជូននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុដ៏ពេញចិត្ត មានគុណភាពខ្ពស់ និងអាចជឿទុកចិត្តបានដល់អតិថិជនដែលមានប្រវត្តិឥណទានល្អ មុខរបរស្របច្បាប់ និងសមត្ថភាពក្នុងការទូទាត់សង។

យុទ្ធសាស្ត្រអាជីវកម្មរបស់យើងគឺ នាំមកនូវគុណតម្លៃដល់សហគមន៍ និងផ្តល់ជូនអតិថិជននូវផលិតផលហិរញ្ញវត្ថុដែលអតិថិជនត្រូវការ ប្រកបដោយភាពស្មោះត្រង់ និងទុកចិត្ត។

គណៈគ្រប់គ្រងរបស់យើង បាននឹងបន្តកិច្ចសហប្រតិបត្តិដើម្បីលើកទឹកចិត្តអតិថិជន នៅក្នុងព្រះរាជាណាចក្រកម្ពុជាអោយទទួលបាននូវប្រាក់កម្ចីទិញគេហដ្ឋាន និងវីឡា ដែលមានទំហំកម្ចីរហូតដល់ ១០០% (មួយរយភាគរយ) នៃតម្លៃគេហដ្ឋាន ដែលត្រូវបានប្រើប្រាស់ចំពោះគម្រោងអភិវឌ្ឍផ្ទះ និងវីឡា របស់ដៃគូជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក យើងខ្ញុំ។

សូមអរគុណចំពោះការចំណាយពេលដ៏មានតម្លៃ របស់អ្នកក្នុងការអានរបាយការណ៍ប្រចាំឆ្នាំ និងការចូលមើលគេហទំព័ររបស់យើងខ្ញុំ។ សូមសំណាងល្អ និងរីករាយឆ្នាំថ្មី។

សូមអរគុណ!

លោក ឧកញ៉ា តាំង គួងបាវ
ប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

# សាររបស់នាយកប្រតិបត្តិ



តំណាងឱ្យគណៈគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេច ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាងកញ្ញា និងអតិថិជនជាទីស្រឡាញ់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអានរបាយការណ៍ប្រចាំឆ្នាំ និងបានផ្តល់-ទទួលសេវាកម្មជាមួយគ្រឹះស្ថានយើងខ្ញុំ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាផ្នែកមួយនៃអង្គភាពសេដ្ឋកិច្ច និងជាអន្តរការីហិរញ្ញវត្ថុដើម្បីជួយដល់ប្រជាជន ចំពោះតម្រូវការដំណោះស្រាយផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេស។

ជាក់ស្តែងក្នុងឆ្នាំ២០២១នេះ វីរុសរាតត្បាតសកលនៃជំងឺកូវីដ១៩នៅតែបន្ត និងបានបង្កផលប៉ះពាល់ដល់ច្រើនវិស័យ នៃខឿនសេដ្ឋកិច្ចកម្ពុជា រួមទាំងផលប៉ះពាល់ដល់ការប្រកបរបរប្រចាំថ្ងៃរបស់ប្រជាជនផងដែរ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានចូលរួមផ្តល់ដំណោះស្រាយហិរញ្ញវត្ថុ ចំពោះអតិថិជនដែលទទួលរងផលប៉ះពាល់ជំងឺកូវីដ១៩ តាមរយៈការផ្តល់ឥណទានរៀបចំឡើងវិញ និងអនុគ្រោះសោហ៊ុយផ្សេងៗជាដើម។

គ្រឹះស្ថានយើងមានបំណងរក្សាចេរភាពផលិតផល និងសេវាកម្មហិរញ្ញវត្ថុជូនដល់អតិថិជន ដោយលើកទឹកចិត្តដល់អតិថិជនបង្កើនទ្រព្យសម្បត្តិឱ្យប្រសើរជាងមុនតាមរយៈដំណោះស្រាយហិរញ្ញវត្ថុ និងលើកកម្ពស់សេវាកម្មហិរញ្ញវត្ថុ ក្នុងដំណើរការរយៈពេលវែងជាមួយគ្រឹះស្ថានរបស់យើងខ្ញុំ។ ម្ចាស់ភាគហ៊ុន នៃគ្រឹះស្ថានមានបំណង រួមចំណែកក្នុងផ្នែកសេវាកម្មហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍស្ថានភាពរស់នៅរបស់ប្រជាជនចាប់ពីកម្រិតចំណូលទាបឡើងទៅ និងដើម្បីគាំទ្រដល់ផែនការអភិវឌ្ឍប្រទេសរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជនដែលកំពុងប្រើសេវាកម្ម និងមានគម្រោងប្រើសេវាកម្មហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក នៅថ្ងៃអនាគត ដើម្បីទទួលបានកំណើនសេដ្ឋកិច្ចក្នុងគ្រួសារ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ រួមទាំងធនាគារជាតិ នៃ កម្ពុជា ដែលបានសហការ និងគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ ក្នុងការគ្រប់គ្រងដំណើរការល្អប្រសើរ និងតម្លាភាពដល់អតិថិជនរបស់យើងហើយនឹងបន្តទៅអនាគត។

សូមជូនពរ សូមទទួលបានជោគជ័យ សុភមង្គល និងបានសុខចម្រើនគ្រប់ៗគ្នា។ ដោយក្តីគោរពពីខ្ញុំ !



**ជេដ្ឋ គីមឌិន**
នាយកប្រតិបត្តិ

គ្រឹះស្ថាននឹងត្រូវបានទទួលស្គាល់ពេញផ្ទៃប្រទេស ថាជាគ្រឹះស្ថានដ៏ធំមួយក្នុងចំណោមគ្រឹះស្ថានធំៗផ្នែកខាងប្រាក់កម្ចីគេហដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។



មានជំនាញនិងចំណេះដឹងខ្ពស់នៅក្នុងវិស័យឥណទានគេហដ្ឋាន។



បង្កើតស្តង់ដារថ្មីជាបន្តបន្ទាប់ដើម្បីអភិវឌ្ឍសេវាកម្មប្រាក់កម្ចីគេហដ្ឋានក្នុងប្រទេស។




ប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណេតនិងប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីផ្តល់ការអនុម័តនិងការទូទាត់ផ្នែកហិរញ្ញវត្ថុបានឆាប់រហ័ស។

## សោមនស្សរីករាយក្នុងការលើកទឹកចិត្តអតិថិជននិងដៃគូក្នុងការបង្កើនទ្រព្យសម្បត្តិ ៖

- រក្សាភាពងាយស្រួល មានលក្ខខណ្ឌតាមច្បាប់ អតិថិជនអាចទទួលបានការអនុម័តឥណទានបានឆាប់រហ័ស។
- ផ្តល់សេវាដោយឥតគិតថ្លៃសម្រាប់ ការពិគ្រោះយោបល់ផ្នែកច្បាប់ដើម្បីទទួលបានភាពជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យ។
- សម្រួលនូវការសងប្រាក់ត្រឡប់បត់បែនទាំងលើការប្រាក់និងប្រាក់ដើមសម្រាប់អតិថិជន។
- ផ្តល់អត្ថប្រយោជន៍ដល់អតិថិជន ដៃគូសហការ និងអ្នកពាក់ព័ន្ធ។

## ប្រតិបត្តិការប្រកបដោយក្រមសីលធម៌ដើម្បីជាប្រយោជន៍ដល់សហគមន៍ ៖

- គាំទ្រផ្នែកលំនៅដ្ឋានដល់យុវជនដែលបានចាប់ផ្តើមបង្កើតក្រុមគ្រួសារថ្មី។
- ផ្តល់ការប្រឹក្សាដោយឥតគិតថ្លៃដើម្បីទទួលបានប្រាក់កម្ចីគេហដ្ឋាន។
- ផ្តល់អាទិភាពឱ្យបុគ្គលិកផ្ទៃក្នុងនូវឱកាសឋានៈការងារនិងទទួលបានអត្ថប្រយោជន៍មុនបុគ្គលិកមានប្រភពពីខាងក្រៅ។
- ជួយមនុស្សពេញវ័យដែលកំពុងស្វែងរកបទពិសោធន៍ការងារឱ្យមានឱកាស។
- លើកកម្ពស់ការអនុវត្ត និងការប្រកួតប្រជែងល្អនៅក្នុងឧស្សាហកម្មប្រាក់កម្ចីគេហដ្ឋាន។




គោលបំណងនៃការធ្វើយុទ្ធសាស្ត្រ គឺត្រូវអនុវត្តតាមតម្លៃស្នូលដែលបានតាក់តែងឡើង ដើម្បីបង្កើតវិធីសាស្ត្រគ្រប់គ្រងអភិវឌ្ឍ ដោយរក្សានូវការជឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន និងតាមកាលៈទេសៈ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

**G B MICROFINANCE INSTITUTION PLC.**

# រចនាសម្ព័ន្ធគ្រប់គ្រង




ការិយាល័យកណ្តាល: អគារលេខ ចេ៣៧ ផ្លូវលំ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
ទូរស័ព្ទលេខ:(+៨៥៥) ២៣ ៩៧៧ ៧៧៨/៩៩ ៥៧០ ៥៥៥, www.gbmfi.com.kh, E-mail: info@gbmfi.com.kh
Facebook Page: facebook.com/gbmicrofinance

## លោក ឧកញ៉ា តាំង គួងបាវ

### ប្រធានក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក



លោក ឧកញ៉ា តាំង គួងបាវ ជាសហាភាគហ៊ុនិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក និងមានភារកិច្ចជាអ្នកសហាការអនុម័តនិងសម្រេចចិត្តស្នូល ដូចជាការទទួលយកការវិនិយោគពីអ្នកវិនិយោគិនក្នុងស្រុក និងបរទេស ការបង្កើនដើមទុនសម្រាប់គ្រឹះស្ថាន និងការពង្រីកប្រតិបត្តិការអាជីវកម្ម នៅក្នុងប្រទេសនិងក្រៅប្រទេសកម្ពុជា។

លើសពីនេះលោក ឧកញ៉ា គឺជាវិនិយោគិនវិស័យធុរកិច្ចផ្សេងទៀតផងដែរដូចជា រោងចក្រវ៉ៃ និងថ្មម៉ាប វិស័យអចលនទ្រព្យ វិស័យអភិវឌ្ឍលំនៅដ្ឋាន ឧស្សាហកម្មកសិកម្ម និងវិស័យសេវាកម្មហិរញ្ញវត្ថុ ដែលគ្របដណ្តប់ក្រោមកម្មសិទ្ធិបញ្ញាម៉ាកយីហោឈ្មោះ ជី ប៊ី (G B)។ នៅក្នុងនោះដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក៏ជាផ្នែកមួយនៃឈ្មោះនេះដែរ។

លោក ឧកញ៉ា តាំង គួងបាវ មានឆន្ទៈក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការនាំយកឱកាសអាជីវកម្មសម្រាប់សហាគមន៍ និងគាំទ្រដល់យុទ្ធសាស្រ្តនានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។



## លោកស្រី HSU, CHIA-CHIA

### អនុប្រធានក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក



លោកស្រី HSU, CHIA-CHIA ជាសហភាគហ៊ុនិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក និងមានភារកិច្ចជាអ្នកសហការអនុម័តនិងសម្រេចចិត្តស្នូល ដូចជាការទទួលយកការវិនិយោគពីវិនិយោគិនក្នុងស្រុក និងបរទេស ការបង្កើនដើមទុនសម្រាប់គ្រឹះស្ថាន និងការពង្រីកប្រតិបត្តិការអាជីវកម្មនៅទូទាំងក្នុងប្រទេស និងក្រៅប្រទេសកម្ពុជា។

លើសពីនេះ លោកស្រីគឺជាវិនិយោគិនវិស័យផ្សេងៗទៀតផងដែរដូចជា សណ្ឋាគារ(A+) អចលនទ្រព្យ អភិវឌ្ឍលំនៅដ្ឋាន ឧស្សាហកម្មកសិកម្ម។ លោកស្រី HSU, CHIA-CHIA ក៏មានចក្ខុវិស័យអំពីការចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមនៃប្រទេសកម្ពុជា តាមរយៈការលើកទឹកចិត្ត និងគៀងគរវិនិយោគិនក្រៅប្រទេសបន្ថែមទៀត មកបណ្តាក់ទុនក្នុងឱកាសអាជីវកម្មថ្មីៗ នៅព្រះរាជាណាចក្រកម្ពុជា និងគាំទ្រដល់យុទ្ធសាស្ត្រនានា របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។



## លោក តាំង កៅគៀត

**សមាជិកក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**



លោក តាំង កៅគៀត ជាសមាជិកក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ហើយក៏ជាទីប្រឹក្សារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ផងដែរ។ តួនាទីរបស់លោកគឺជាអ្នកចូលរួមត្រួតពិនិត្យ ផ្តល់យោបល់ ការណែនាំ ផ្តល់ការគាំទ្រ ដើម្បីធានាបានជោគជ័យចំពោះ ប្រតិបត្តិការរបស់គ្រឹះស្ថាន។

លោក តាំង កៅគៀត បច្ចុប្បន្នគឺជានាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន ហ្វាយស្តារ រេស៊ីដេន អេសអ ឯ.ក និងក្រុមហ៊ុនជីប៊ី រ៉េស៊ីដេន ឯ.ក។

លោកមានបទពិសោធន៍ការងារជាច្រើនទៀត ក្នុងវិស័យធុរកិច្ចពាណិជ្ជកម្ម រួមទាំងវិស័យដឹកជញ្ជូន និងសំណង់ វិស័យសេវាកម្មហិរញ្ញវត្ថុ ការគ្រប់គ្រងពហុក្រុមហ៊ុនបុត្រសម្ព័ន្ធ និងទំនាក់ទំនងអន្តរជាតិ ដែលអាចធានាបានចំពោះក្រុមហ៊ុនឆ្ពោះទៅរកចក្ខុវិស័យ និងបេសកកម្មត្រឹមត្រូវ ព្រមទាំងនិរន្តរភាពរបស់ក្រុមហ៊ុនទៅថ្ងៃអនាគត។



## លោក ម៉ាក ចំរើន

### សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក



លោក ម៉ាក ចំរើន គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក។ លោកមានភារកិច្ចស្នូល ចូលរួមក្នុងការសម្រេចចិត្ត និងសហការអនុម័តលើផែនការអាជីវកម្ម គោលនយោបាយ និងចក្ខុវិស័យអាជីវកម្ម និងប្រតិបត្តិការរបស់ក្រុមហ៊ុន។

លើសពីនេះ លោកគឺជាប្រធានគណៈកម្មការសវនកម្មផ្ទៃក្នុង និង ជាគណៈត្រួតពិនិត្យកិច្ចការប្រតិបត្តិតាម រួមទាំងធ្វើជាអ្នកផ្តល់អនុសាសន៍ដល់អង្គប្រជុំក្រុមប្រឹក្សាភិបាល អំពីយន្តការហិរញ្ញវត្ថុ និងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុគោលនយោបាយប្រតិបត្តិការ រួមទាំងការកំណត់អំណាចរបស់ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិក្នុងការដោះស្រាយបំណុលសាជីវកម្ម ប្រាក់កម្ចីសង្ស័យ និងហានិភ័យហិរញ្ញវត្ថុផ្សេងទៀតផងដែរ។

លោក ម៉ាក ចំរើន បច្ចុប្បន្នជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន អាហ្គ្រីប៊ី (ខេមបូឌា) ភីអិលស៊ី និងជា នាយកប្រតិបត្តិនៃក្រុមហ៊ុន FinTech Smile Shop E-Commerce Platform ។

លោកធ្លាប់ជាប្រធាននាយកដ្ឋានអភិវឌ្ឍស្ថាប័ន និងទំនាក់ទំនងបុគ្គលិក និងជាប្រធាននាយកដ្ឋានទីផ្សាររបស់ធនាគារ ស៊ីអាយអឹមប៊ី ភីអិលស៊ី (CIMB Bank Plc.) ក្នុងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦។ លោកក៏មានអតីតភាពជាប្រធានសមាគមយុវជនខ្មែរ (KYA) ក្នុងឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ ផងដែរ។






## លោក ជេដ្ឋ គីមជិន
### នាយកប្រតិបត្តិ



លោក ជេដ្ឋ គីមជិន បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងខែកញ្ញា ឆ្នាំ២០១៩ ក្នុងតួនាទីជានាយកប្រតិបត្តិ ដែលលោកត្រូវបានទទួលស្គាល់ដោយធនាគារជាតិ នៃ កម្ពុជា។

លោក ជេដ្ឋ គីមជិន មានបទពិសោធន៍ និងចំណេះដឹងនៅក្នុងឧស្សាហកម្មសេវាកម្មហិរញ្ញវត្ថុ រយៈពេលជាង២០ឆ្នាំលើសមត្ថភាពផ្សេងៗគ្នារួមមាន ៖

ការអភិវឌ្ឍអាជីវកម្ម ទីផ្សារនិងការលក់ ការគ្រប់គ្រងឥណទាន ការគ្រប់គ្រងធនាគារ និងហិរញ្ញវត្ថុ។

លោក ជេដ្ឋ គីមជិន ធ្លាប់បានចូលបម្រើការងារផ្នែកសេវាកម្មហិរញ្ញវត្ថុ នៅធនាគារពាណិជ្ជ នាឆ្នាំ១៩៩៩ ហើយបន្ទាប់មក លោកត្រូវបានជ្រើសតាំងជាប្រធានសាខានៃធនាគារពាណិជ្ជនៅឆ្នាំ២០០៧។ ឆ្នាំ២០១៨ លោកបានក្លាយជា នាយកប្រតិបត្តិ នៃក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅភ្នំពេញតរៀងមក។

លោក ជេដ្ឋ គីមជិន បានទទួលបរិញ្ញាបត្រផ្នែកអភិវឌ្ឍសេដ្ឋកិច្ចពីវិទ្យាស្ថានអន្តរជាតិនៃកម្ពុជាក្នុងឆ្នាំ២០០៣ និងអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ និងធនាគារពីវិទ្យាស្ថានអន្តរជាតិសិង្ហបុរីនៅកម្ពុជាក្នុងឆ្នាំ២០០៦។

លោកបានទទួលលិខិតបញ្ជាក់ អំពីការសិក្សាវគ្គជំនាញ វគ្គចំប៉ន សិក្ខាសាលាជាច្រើនផ្សេងទៀតដែលទាក់ទងនឹងវិស័យសេវាកម្មហិរញ្ញវត្ថុ ឧស្សាហកម្មពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះលោកបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាមួយចំនួនទាក់ទងនឹងសេវាកម្មហិរញ្ញវត្ថុ ធនាគារ និងពាណិជ្ជកម្មអន្តរជាតិនៅប្រទេសចិន ម៉ាឡេស៊ី ថៃ និងប្រទេសវៀតណាមផងដែរ។



## អ្នកស្រី ប្អូន ច័ន្ទសុភា
### ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ



អ្នកស្រី ប្អូន ច័ន្ទសុភា មានបទពិសោធន៍ការងាររយៈពេលជាង១៨ឆ្នាំ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ រួមមាន១២ឆ្នាំ បានបម្រើការងារនៅធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

អ្នកស្រី ធ្លាប់ជាគណនេយ្យករម្នាក់បម្រើការងារ នៅអង្គការក្រៅរដ្ឋាភិបាលក្នុងឆ្នាំ២០០៨។

បន្ទាប់មក អ្នកស្រីបានចូលបម្រើការងារនៅធនាគារ អេស៊ីលីដា ភីអិលស៊ី នាឆ្នាំ២០០៧ ជាគណនេយ្យកររយៈពេល៩ឆ្នាំ។ អ្នកស្រីបានចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ក្នុងមុខងារជាប្រធានគណនេយ្យករនៅឆ្នាំ២០១៦ និងត្រូវបានដំឡើងតួនាទីជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។

អ្នកស្រី ប្អូន ច័ន្ទសុភា មានជំនាញក្នុងវិស័យហិរញ្ញវត្ថុដូចជា ការរៀបចំផែនការគម្រោងហិរញ្ញវត្ថុ ផែនការអាជីវកម្ម និងការវិភាគថវិកា។ អ្នកស្រីជាអ្នកជំនាញផ្នែក ការងារប្រកាសពន្ធទៅអគ្គនាយកដ្ឋានពន្ធដារកម្ពុជា ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ធនាគារជាតិ នៃកម្ពុជា និងរៀបចំរបាយការណ៍សម្រាប់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុន។ លើសពីនេះទៅទៀត អ្នកស្រីក៏ជាអ្នកជំនាញផ្នែកអភិវឌ្ឍគោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុ និងគណនេយ្យសម្រាប់គ្រឹះស្ថានផងដែរ។

អ្នកស្រី ប្អូន ច័ន្ទសុភា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៃ កម្ពុជា (NUM) នៅក្នុងឆ្នាំ២០០៦ ហើយអ្នកស្រី បានទទួលសញ្ញាបត្រជាន់ខ្ពស់ភាសាអង់គ្លេស ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៃ កម្ពុជា នៅឆ្នាំ២០១២។ លើសពីនេះទៀត អ្នកស្រីបានចូលរួមវគ្គសិក្សា និងសិក្ខាសាលាជាច្រើនទាក់ទងនឹងកិច្ចការធនាគារ និងមីក្រូហិរញ្ញវត្ថុទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។

បច្ចុប្បន្នអ្នកស្រី បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្នុងខែកញ្ញា ឆ្នាំ២០១៩ ។

## លោក ហ៊ត សុវណ្ណឌី
### ប្រធាននាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស



បួនឆ្នាំបន្ទាប់លោក ហ៊ត សុវណ្ណឌី បានក្លាយជាប្រធាននាយកដ្ឋានធនធានមនុស្សនិងរដ្ឋបាល នៅក្នុងក្រុមហ៊ុនឯកជន ដែលមានក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើនស្ថិតនៅខាងក្រោមបន្ទុក។

លោក ហ៊ត សុវណ្ណឌី បានបញ្ចប់ថ្នាក់បរិញ្ញាបត្រពាណិជ្ជកម្មផ្នែកហិរញ្ញវត្ថុ និងគណនេយ្យនៅឆ្នាំ២០០៧នៅសាកលវិទ្យាល័យបៀលប្រាយ និងបានបញ្ចប់ថ្នាក់សញ្ញាបត្រភាសាអង់គ្លេស នៅវិទ្យាស្ថានអន្តរជាតិអប់រំកម្ពុជា ២០០៨។ លើសពីនេះទៀត លោក ហ៊ត សុវណ្ណឌី ក៏បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រងធនធានមនុស្សផងដែរ។

លោក ហ៊ត សុវណ្ណឌី បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ធ.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នាចុងខែធ្នូ ឆ្នាំ២០២១។

លោក ហ៊ត សុវណ្ណឌី មានបទពិសោធន៍ការងារជាង១៨ឆ្នាំលើការងារ ផ្នែកធនធានមនុស្ស និងរដ្ឋបាល។ ចាប់ផ្តើមការងារជារដ្ឋបាល និងជាអ្នកគណនាប្រាក់បៀវត្សប្រចាំរោងចក្រកាត់ដេរ និងរោងចក្រផលិតចំណីសត្វអស់រយៈពេលបួនឆ្នាំ លោក ហ៊ត វណ្ណឌី បានអភិវឌ្ឍខ្លួនដោយផ្លាស់ប្តូរការងារពីវិស័យឧស្សាហកម្មកាត់ដេរ និងផលិតចំណីសត្វទៅកាន់ការងារជាមន្ត្រីជំនាញ ផ្នែកធនធានមនុស្ស និងជាជំនួយការអ្នកគ្រប់គ្រងធនធានមនុស្ស នៅក្រុមហ៊ុនទូរគមនាគមន៍អន្តរជាតិក្នុងស្រុកបានរយៈពេលជាង៦ឆ្នាំ។



## លោក ប៉ៃ ឡាតែន

### ប្រធាននាយកដ្ឋានព័ត៌មានវិទ្យាស្ថិទី



លោក ប៉ៃ ឡាតែន មានបទពិសោធន៍ការងាររយៈពេលជាង៦ឆ្នាំ លើផ្នែកខាងអភិវឌ្ឍប្រព័ន្ធកម្មវិធីនិងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលក្នុងនោះគឺ៣ឆ្នាំលោកបានបម្រើការនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្រៅពីកិច្ចការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លោកក៏ជាអ្នកអភិវឌ្ឍប្រព័ន្ធកម្មវិធី និងរចនាគេហទំព័រអោយ ក្រុមហ៊ុនឯកជនផងដែរ។

លោក ប៉ៃ ឡាតែន បានទទួលបរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០១៧ ហើយ លោកបានកំពុងបន្តការសិក្សាថ្នាក់អនុបណ្ឌិតព័ត៌មានវិទ្យានៅសាកលវិទ្យាល័យអាស៊ី អឺរ៉ុប ក្នុងឆ្នាំសិក្សា ២០២០ - ២០២២។

លោក ប៉ៃ ឡាតែន ក៏បានចូលរួមវគ្គបណ្តុះបណ្តាលដូចជាភាពជាអ្នកដឹកនាំនៅប្រទេសសិង្ហបុរី បានចូលរួមសិក្សាវគ្គគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា ការគ្រប់គ្រងព័ត៌មានវិទ្យាផ្នែករចនាគេហទំព័រ និងIntegration and Administration ED3, People Soft Integration Tools Rel 8.53, Oracle Database 12c Release, People Soft Lifecycle Management and Update Manager, Oracle Database Security Release 2, Microsoft Office 365, Training Engineering and leadership និង Android App Development (CKCC)។

លោក ប៉ៃ ឡាតែន បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យាស្ថិទី នៅក្នុងខែតុលា ឆ្នាំ២០២១។



## លោក ឡេង សុវណ្ណារ៉ាត់

### ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម



លោក ឡេង សុវណ្ណារ៉ាត់ បានចូលបម្រើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក នាខែវិច្ឆិកា ឆ្នាំ២០២១ ដោយ លោកត្រូវបានធនាគារជាតិ នៃ កម្ពុជា ទទួលស្គាល់ថាជាបេក្ខជនមានសមត្ថភាពក្នុងតួនាទី ជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមរបស់គ្រឹះស្ថាន។

លោក ឡេង សុវណ្ណារ៉ាត់ មានបទពិសោធន៏រយៈជាង១៨ឆ្នាំ ផ្នែកគ្រប់គ្រងហានិភ័យធនាគារ និងហិរញ្ញវត្ថុ ការត្រួតពិនិត្យអនុលោមបញ្ញត្តិ ទប់ស្កាត់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា។

លោក ឡេង សុវណ្ណារ៉ាត់ មានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ដោយធ្លាប់ទទួលបន្ទុកលើមុខងារជាច្រើនដូចជា ផ្នែកគណនេយ្យ ផ្នែកប្រតិបត្តិការ ឯកទេសជាន់ខ្ពស់វិភាគហិរញ្ញវត្ថុនិងផែនការថវិការ គ្រប់គ្រងហានិភ័យ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រួតពិនិត្យអនុលោមបញ្ញត្តិ និងបទពិសោធន៍ជាច្រើនជាមួយអតិថិជន។ តួនាទីចុងក្រោយរបស់លោក គឺជាអ្នកដឹកនាំនិងគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិតាម នៃធនាគារពាណិជ្ជមួយ និងទទួលបានជោគជ័យក្នុងការដឹកនាំរៀបចំបង្កើតនូវយុទ្ធសាស្ត្រធនាគារ គោលនយោបាយ និងនីតិវិធីសំខាន់ៗមួយចំនួន ជាមួយគម្រោងរបស់ស្ថាប័នអន្តរជាតិហៅកាត់ AFD។

លោក ឡេង សុវណ្ណារ៉ាត់ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ នៅខែមីនា ឆ្នាំ២០១២ បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ នៅខែកក្កដា ឆ្នាំ២០០៣ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ នៅឆ្នាំ២០១៩ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ទាក់ទងនឹងការគ្រប់គ្រងធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាមដែលបានទទួលស្គាល់ដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ហៅកាត់ថាIBF។ លើសពីនេះទៅទៀតលោក ឡេង សុវណ្ណារ៉ាត់ បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនដូចជាគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម យុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាននិងសង្គម ពីប្រទេសហ្វីលីពីន ការគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ ប្រព័ន្ធហិរញ្ញវត្ថុសកលនិងទីផ្សារហិរញ្ញវត្ថុ គ្រប់គ្រងហានិភ័យនៃប្រព័ន្ធប្តូរប្រាក់ ការព្យាករណ៍និងការគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ចសកល ការគ្រប់គ្រងពន្ធនិងច្បាប់សារពើពន្ធរបស់ប្រទេសកម្ពុជា ការអភិវឌ្ឍជំនាញវិជ្ជាជីវៈក្នុងវិស័យហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្មនិងបំណុលរបស់ធនាគារ អភិវឌ្ឍប្រព័ន្ធបទដ្ឋានរបាយការណ៍គណនេយ្យអន្តរជាតិ ”IFRS” ការវាយតម្លៃអញ្ញមញ្ញ និងការវាយតម្លៃហានិភ័យថ្នាក់ជាតិរបស់ធនាគារពិភពលោកនិងក្រុមការងារAPG។

## លោក យក់ សារឿន
### ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង



លោក យក់ សារឿន បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ក្នុងមុខតំណែងជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នាខែកញ្ញា ឆ្នាំ២០១៩។

លោកត្រូវបានធនាគារជាតិ នៃ កម្ពុជា ទទួលស្គាល់ជាបេក្ខជនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញតួនាទីជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន។

លោក យក់ សារឿន មានបទពិសោធន៍ការងាររយៈពេលជាង១៨ឆ្នាំ ទាក់ទងនឹងផ្នែកសេវាកម្មហិរញ្ញវត្ថុ ធនាគារ និងមីក្រូហិរញ្ញវត្ថុ ដោយលោកបានចាប់ផ្ដើមការងារដំបូងជាមន្ត្រីឥណទាន នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់រយៈពេលជិត៣ឆ្នាំ។ បន្ទាប់មក លោកបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត ក្នុងឆ្នាំ២០១០ ជាគណនេយ្យករ។ លោកក៏ត្រូវបានដំឡើង ឋានៈជាប្រធានផ្នែកសវនកម្មហិរញ្ញវត្ថុនៅឆ្នាំ២០១៣ នៅក្នុងគ្រឹះស្ថានដដែល។

លោក យក់ សារឿន ធ្លាប់ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង រយៈពេលជាង២ឆ្នាំ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាក់ទីវ ភីភល និងជាជំនួយការនាយកគណនេយ្យនិងហិរញ្ញវត្ថុនៅធនាគារភ្នំពេញពាណិជ្ជ។

លោក យក់ សារឿន បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០១២។ លោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០០៦។

លើសពីនេះ លោកបានចូលរួមសិក្ខាសាលានិងវគ្គបណ្ដុះបណ្ដាលដូចជា៖ គណនេយ្យ ពន្ធដារ សវនកម្មលើបច្ចេកវិទ្យាព័ត៌មាន សវនកម្មពន្ធដារ និងការរៀបចំផែនការពន្ធដារ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រព័ន្ធត្រួតពិនិត្យហានិភ័យ និងការកេងបន្លំ គន្លឹះនៃការគ្រប់គ្រងហានិភ័យ និងវគ្គបណ្ដុះបណ្ដាលផ្សេងៗមួយចំនួនទៀត។

## លោក អ៊ាម ចណ្ណា
### ប្រធាននាយកដ្ឋានប្រតិបត្តិការឥណទាន



លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកអភិវឌ្ឍជនបទនៅក្នុងឆ្នាំ២០១០ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុនិងធនាគារ នៅក្នុងឆ្នាំ២០១៣ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៃ កម្ពុជា។ លើសពីនេះលោកក៏បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជាច្រើនដែលទាក់ទងនឹងជំនាញ ប្រតិបត្តិការទីផ្សារ ការគ្រប់គ្រងឥណទាន ការគ្រប់គ្រងសាខា និងការគ្រប់គ្រងប្រាក់កម្ចីដែលធ្វើឡើងដោយផ្ទៃក្នុងគ្រឹះស្ថាន និងវិទ្យាស្ថានដៃគូនៅប្រទេសកម្ពុជា។

លោក អ៊ាម ចណ្ណា មានបទពិសោធន៍ការងាររយៈពេលជាង៨ឆ្នាំ ទាក់ទងនឹងវិស័យហិរញ្ញវត្ថុនិងប្រតិបត្តិការឥណទានធនាគារនិងមីក្រូហិរញ្ញវត្ថុ។ លោក អ៊ាម ចណ្ណា ធ្លាប់ជាប្រធានសាខានៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី ក្នុងឆ្នាំ២០១៨។ លោកត្រូវបានផ្លាស់ប្តូរទៅនាយកដ្ឋានអភិវឌ្ឍអាជីវកម្ម នៅគ្រឹះស្ថាន ដដែលនៅឆ្នាំ ២០១៩ ដើម្បីចូលរួមរៀបចំផែនការយុទ្ធសាស្ត្រនិងជំរុញសកម្មភាពរបស់គ្រឹះស្ថាន ឱ្យសម្រេចគោលដៅប្រកបដោយប្រសិទ្ធភាព និងមានគុណភាពដល់ផលប័ត្រកម្ចីរបស់គ្រឹះស្ថាន។



លោក អ៊ាម ចណ្ណា បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ជាអនុប្រធាននាយកដ្ឋានប្រតិបត្តិការឥណទាន ក្នុងខែធ្នូ ឆ្នាំ២០១៩។ តាមរយៈស្នាដៃនិងលទ្ធផលការងារទទួលបានក្នុងរយៈពេលជិត២ឆ្នាំ លោក អ៊ាម ចណ្ណា ត្រូវបានតែងតាំងជា ប្រធាននាយកដ្ឋានប្រតិបត្តិការឥណទាន នាចុងខែធ្នូ ឆ្នាំ២០២១។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានជ្រើសយកដៃគូអាជីវកម្មផ្នែកអភិវឌ្ឍលំនៅដ្ឋានដ៏មានជំនាញក្នុងការសាងសង់លំនៅដ្ឋាន មានហេដ្ឋារចនាសម្ព័ន្ធធំទូលាយ សំណង់ល្អប្រណិត និងមានផាសុខភាពល្អ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ផ្តល់ឥណទានទិញគេហដ្ឋានដូចជាការទិញគេហដ្ឋានបែបលំនៅដ្ឋាន គេហដ្ឋានសម្រាប់ប្រកបអាជីវកម្មនិងគេហដ្ឋានបែបវីឡាជាដើម។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ផ្តល់ប្រាក់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម ដូចជាសហគ្រាសម្ហូបអាហារ និងភេសជ្ជៈ វាយនភណ្ឌ គ្រឿងសង្ហារឹម ផលិតផលក្រដាស ការបោះពុម្ព និងការបោះពុម្ពផ្សាយ រោងចក្រផលិតប្លាស្ទិក រោងចក្រផលិត ផលិតផលដែក និងការផលិតផ្សេងៗទៀត។ល។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានបង្កើតកម្មវិធីប្រាក់កម្ចីផ្ទាល់ខ្លួនដ៏ប្រណិត មានប្រសិទ្ធភាពនិងទូលំទូលាយ ដើម្បីបំពេញតម្រូវការរបស់អតិថិជន។ សេវាកម្មប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក មានដូចជាការទិញសម្ភារៈដាក់ផ្ទះ ការជួសជុលផ្ទះ ការពង្រីកអាជីវកម្មខ្នាតតូច និងគោលបំណងផ្ទាល់ខ្លួនផ្សេងទៀត។ល។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានបង្កើតកម្មវិធីប្រាក់កម្ចីបុគ្គលិក ដើម្បីជួយសម្រួលផ្នែកខ្លះនៃតម្រូវការហិរញ្ញវត្ថុចាំបាច់ក្នុងជីវភាពរស់នៅរបស់បុគ្គលិក។ តាមរយៈឥណទាននេះ បុគ្គលិកអាចបំពេញកង្វះខាតក្នុងការជួសជុល កែលំអរគេហដ្ឋាន ទិញគេហដ្ឋានឬទិញដី យានជំនិះ ម៉ូតូ រថយន្ត បង់ថ្លៃសាលា ព្យាបាលជំងឺសាច់ញាតិបងប្អូន។ល។

## គ្រឹះស្ថានបានអនុវត្ត អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានាដូចជា៖

- ប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ស្ដីពី ការផ្ដល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០៦-២០៩ ប្រ.ក ស្ដីពី ការកែសម្រួលប្រកាសស្ដីពីការផ្ដល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០៨-២១១ ប្រ.ក ស្ដីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០២-៨៨ ប្រ.ក ស្ដីពី អនុបាតសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០៧-១៣៣ ប្រ.ក ស្ដីពី សាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០៧-១៣២ ប្រ.ក ស្ដីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០២-៨៧ ប្រ.ក ស្ដីពី តម្រូវការរបាយការណ៍សម្រាប់ប្រតិបត្តិករគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។
- ប្រកាសលេខ ធ៧-០៦-២១២ ប្រ.ក ស្ដីពី កាលបរិច្ឆេទផ្ញើរបាយការណ៍ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០១៧-៣៨៨ ប្រ.ក ស្ដីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអីមតែរមិន។
- សារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណា ស្ដីពី ការអនុវត្តប្រកាសស្ដីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអីមតែរមិន។
- ប្រកាសលេខ ធ៧-០១៧-១០៩ ប្រ.ក ស្ដីពី ការកំណត់ពិដានអត្រាការប្រាក់ឥណទាន។
- ប្រកាសលេខ ធ៧-០២០-៣៥២ ប្រ.ក ស្ដីពី ការចែករំលែកព័ត៌មានឥណទាន។

## គ្រឹះស្ថានបានអនុវត្ត អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានាដូចជា៖



- ប្រកាសលេខ ធ៧-០៩-០៧៥ ប្រ.ក ស្តីពីការផ្តល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- ប្រកាសលេខ ធ៧-០១៧-២៩៩ ប្រ.ក ស្តីពីការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ២៧ មិថុនា ឆ្នាំ២០២០។
- សេចក្តីណែនាំ ស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន។
- សេចក្តីណែនាំស្តីពីការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យរបស់បុគ្គលរាយការណ៍។
- ប្រកាសលេខ ១៨៥៩ សហវ.ប្រក ស្តីពីការអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលសហរដ្ឋអាមេរិច ដើម្បីធ្វើឲ្យប្រសើរឡើងនូវអនុលោមភាពពន្ធអន្តរជាតិ និងអនុវត្តច្បាប់ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិច។
- នីតិវិធីនៃការបញ្ជូនរបាយការណ៍ FATCA មកអគ្គនាយកដ្ឋានពន្ធដារ។
- សេចក្តីជូនដំណឹងលេខ ០១២ អពដ ស្តីពី គោលការណ៍ណែនាំទាក់ទិននឹងការទាមទារ និងរាយការណ៍អំពី លេខអត្តសញ្ញាណកម្មសារពើពន្ធអ្នកជាប់ពន្ធជនជាតិអាមេរិច(U.S. TIN)។
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។
- ប្រកាសស្តីពីការផ្តល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។
- ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។
- ច្បាប់ និងវិសោធនកម្មស្តីពីការងារ។
- ប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន។
- ប្រកាស ស្តីពីប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន។
- ប្រកាស ស្តីពីការពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ។
- ប្រកាស ស្តីពីតាវកាលិកហានិភ័យការងារ។
- ប្រកាស ស្តីពីតាវកាលិកថែទាំសុខភាព។

## ពិធីប្រគល់-ទទួលអំណោយថ្នាំគ្រាប់បុរាណចិន របស់លោក ឧកញ៉ា តាំង គួងហាវ ប្រធានក្រុមប្រឹក្សាភិបាលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ជូនដល់ ក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា




លោក ឧកញ៉ា តាំង គួងហាវ ប្រធានក្រុមប្រឹក្សាភិបាល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានអញ្ជើញប្រគល់អំណោយថ្នាំគ្រាប់បុរាណចិន LIANHUA QINGWEN JIAONANG ជូនដល់រាជរដ្ឋាភិបាលតាមរយៈក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អញ្ជើញទទួលថ្នាំគ្រាប់បុរាណចិន LIANHUA QINGWEN JIAONANG ចំនួន ១០.០០០ប្រអប់ នារសៀលថ្ងៃសុក្រ ១ រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែតុលា ឆ្នាំ ២០២១។



## ពិធីប្រគល់-ទទួលអំណោយថ្នាំគ្រាប់បុរាណចិន របស់លោក ឧកញ៉ា តាំង គួងបាវ ប្រធានក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក ជូនដល់ ក្រសួងរ៉ែ និងថាមពល នៃព្រះរាជាណាចក្រកម្ពុជា




លោក ឧកញ៉ា តាំង គួងបាវ ជាប្រធានក្រុមប្រឹក្សាភិបាលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក បានអញ្ជើញប្រគល់អំណោយថ្នាំគ្រាប់បុរាណចិន LIANHUA QINGWEN JIAONANG ជូនដល់រាជរដ្ឋាភិបាលតាមរយៈក្រសួងរ៉ែ និងថាមពល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានអញ្ជើញទទួលថ្នាំគ្រាប់បុរាណចិន LIANHUA QINGWEN JIAONANG ចំនួន២០.០០០ប្រអប់ នាថ្ងៃពុធ ២រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹង ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ដើម្បីចូលរួមចំណែកដល់រាជរដ្ឋាភិបាលក្នុងការព្យាបាលអ្នកជំងឺកូវីដ១៩ ដែលបាននឹងកំពុងរីករាលដាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



# ផ្នែករបាយការណ៍សវនកម្មស្តីអំពី
# របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២១

GB

# ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: ០០០៩៣៩០៩

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមបង្ហាញរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល រួមជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទ និងចុងការិយបរិច្ឆេទបញ្ចប់ត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

### ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងកំឡុងឆ្នាំហិរញ្ញវត្ថុ និងរហូតដល់ចុងកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម:

| | |
|---|---|
| លោក តាំង គួងហាវ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោកស្រី HSU, CHIA-CHIA | អនុប្រធានក្រុមប្រឹក្សាភិបាល |
| លោក តាំង កៅគៀត | អភិបាល |
| លោក ម៉ាក ចំរើន | អភិបាលឯករាជ្យ |

### ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលនៃប្រតិបត្តិការហើយ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនតម្រូវឲ្យ៖

ក) អនុម័តគោលនយោបាយគណនេយ្យសមស្របទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម )CIFRS for SMEs) ដែលតម្រូវឲ្យមានការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល ហើយបន្ទាប់មកត្រូវអនុវត្តគោលនយោបាយទាំងនោះជា អចិន្ត្រៃយ៍។

ខ) អនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និង មធ្យម ឬប្រសិនបើមានគម្លាតពីស្តង់ដារទាំងនេះដែលជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុ គម្លាតទាំងនោះត្រូវបានបង្ហាញ ពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់ចំនួនជាទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ) រក្សាទុកនូវបញ្ជីការគណនេយ្យឲ្យបានត្រឹមត្រូវ និងធានាការគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាព។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៩០៩

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

### ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីដែលមានការសន្មត់ថាក្រុមហ៊ុននឹងមិនបន្តប្រតិបត្តិការនៅអនាគតដ៏ខ្លី និង

ង) បង្កើតគោលនយោបាយទូទៅសម្រាប់ក្រុមហ៊ុន អនុម័តរាល់ការសម្រេចចិត្ត និងសកម្មភាពទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដែលមានផលប៉ះពាល់ជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងការសម្រេចចិត្តទាំងអស់នោះត្រូវបានឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនបានធានាអះអាងថា ក្រុមហ៊ុនបានអនុវត្តទៅតាមលក្ខខណ្ឌចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

តាមគំនិតរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្កើតឡើងស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ដើម្បីផ្តល់នូវទស្សនៈពិត និងត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ។

### ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានយកចិត្តទុកដាក់ទៅលើបញ្ហាដូចខាងក្រោម៖

ក) រាល់សារវន្តទាំងអស់ផ្ទេរទៅ ឬពីទុនបំរុង ឬសំវិធានធនក្នុងឆ្នាំហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ខ) សំវិធានធនគ្រប់គ្រាន់សម្រាប់ការខាតបង់លើគណនីដែលត្រូវទារ និងទ្រព្យសកម្មបច្ចុប្បន្ន និងទ្រព្យអកម្មត្រូវបានអនុវត្តបើសិនបើចាំបាច់។

គ) បំណុលអសារបង់ត្រូវបានលុបចោល ប្រសិនបើមាន

ឃ) វិធីសាស្ត្រនៃការវាយតម្លៃទ្រព្យសកម្ម ឬបំណុលដែលមានស្រាប់គឺមិនខុសឆ្គង ឬមិនសមរម្យ។

ង) មិនមានកាលៈទេសៈណាមួយដែលអាចដឹងពីចំនួនទឹកប្រាក់ណាក៏ដោយ ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលនាំឱ្យមានការភាន់ច្រឡំ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)

លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៩០៩

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

---

### ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ច) មិនមានគម្លាតរវាងរបាយការណ៍ហិរញ្ញវត្ថុចុងការិយបរិច្ឆេទ ធៀបនឹង របាយការណ៍ក្នុងកាលបរិច្ឆេទនេះ ដូចជា ធាតុណាមួយ ប្រតិបត្តិការ ឬ ចំណុចសំខាន់ណាមួយដែលមានលក្ខណៈខុសប្រក្រតី ទៅតាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ដែលនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ក្នុងកំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុដែលរបាយការណ៍វាយការណ៍នេះត្រូវបានធ្វើឡើង។

ឆ) លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងកំឡុងពេល នៃឆ្នាំហិរញ្ញវត្ថុនេះមិនត្រូវបានទទួលរងផលប៉ះពាល់ដោយធាតុណាមួយ ប្រតិបត្តិការ ឬចំណុចសំខាន់ណាមួយដែលមានលក្ខណៈខុសប្រក្រតី។

ជ) គ្មានយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនបានក្លាយទៅជាប្រតិបត្តិ ឬអាចនឹងត្រូវបានអនុវត្តក្នុងកំឡុងពេល ១២ ខែ បន្ទាប់ពីការបញ្ចប់ឆ្នាំហិរញ្ញវត្ថុដែលក្នុងមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នឹងមាន ឬអាចប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលប្រតិបត្តិការនោះដល់កាលកំណត់។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់ជាមួយរបាយការណ៍នេះថាពិតជាបង្ហាញពីទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ហើយនឹងលទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

លោក តាំង គួងហាវ

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២

Crowe

## របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
(លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៩០៩)

Crowe (KH) Co., Ltd
Chartered Accountants
Member Crowe International

Unit 4B, K1 Building (#148), Mao Tse Tung Blvd, Sangkat Toul Tumpung II, Khan Chamkar Morn, Phnom Penh
Kingdom of Cambodia
Main +855 23 216 717
www.crowe.com.kh
info@crowe.com.kh

### ការរាយការណ៍លើរបាយការណ៍ហិរញ្ញវត្ថុ

### ទស្សនៈរបស់សវនករ

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក ហៅថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និង របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនឹង គោលការណ៍គណនេយ្យសំខាន់ៗ ព្រមទាំងកំណត់សម្គាល់ផ្សេងៗដែលមានចាប់ពីទំព័រទី០៩ ដល់ ទំព័រទី៦១។

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុនេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាព ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសធុនតូច និងមធ្យម។

### មូលដ្ឋាននៃទស្សនៈរបស់សវនករ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិ។ ការទទួលខុសត្រូវរបស់ពួកយើងគឺ ស្ថិតនៅក្រោមស្តង់ដារដែលបានចែង និងរៀបរាប់នៅក្នុងផ្នែកទំនួលខុសត្រូវរបស់សវនករទៅលើរបាយការណ៍ ហិរញ្ញវត្ថុនៃរបាយការណ៍សវនកម្មរបស់ពួកយើង។ យើងជឿជាក់ថាភស្តុតាងសវនកម្ម ដែលពួកយើងប្រមូលបាន គឺគ្រប់គ្រាន់ និងសមហេតុផលដើម្បីជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ និងក្រមសីលធម៌

យើងខ្ញុំជាសវនករឯករាជ្យ ដែលតម្រូវឲ្យអនុលោមតាមក្រមសីលធម៌ ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើង ខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយយើងខ្ញុំបានបំពេញនូវរាល់ទំនួលខុសត្រូវនានា ដែលតម្រូវដោយក្រមសីលធម៌នេះផងដែរ។

Crowe

**របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
(លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៩០៩)

**ព័ត៌មានបន្ថែមទៅលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករមានដូចតទៅនេះ**

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន គឺជាអ្នកទទួលខុសត្រូវរាល់ព័ត៌មានដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន។ ព័ត៌មាននោះរួមបញ្ចូលទាំងរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានរួមបញ្ចូលជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឡើយ។

ការបញ្ចេញទស្សនៈរបស់ពួកយើងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនបានរាប់បញ្ចូលជាមួយរបាយការណ៍ក្រុមប្រឹក្សាភិបាលឡើយ ហើយពួកយើងក៏មិនបានបង្ហាញជាលិខិតអះអាងទៅលើការសរុបមតិរបស់របាយការណ៍នោះផងដែរ។

ក្នុងការភ្ជាប់គ្នារវាងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចំពោះទំនួលខុសត្រូវរបស់សវនករ គឺគ្រាន់តែស្វែងយល់អំពី របាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងទទួលយករបាយការណ៍របស់ពួកគាត់ បើទោះបីជារបាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានភាពមិនត្រឹមត្រូវទាក់ទងទៅនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក៏ដោយ ឬក៏មានភាពមិនប្រក្រតីចំពោះវិជ្ជាជីវៈរបស់សវនករដែលបានធ្វើសវនកម្ម ឬក៏ការកើតឡើងនូវភាពខុសប្រក្រតីណាមួយផ្សេងទៀត។

យោងទៅតាមការងារដែលពួកយើងបានបំពេញ ពួកយើងបានសន្និដ្ឋានថា វានឹងមានភាពមិនត្រឹមត្រូវទាក់ទងជាមួយរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ ហេតុដូចនេះហើយទើបបានជាពួកយើងទាមទារនូវរបាយការណ៍ដែលពិតប្រាកដ និងត្រឹមត្រូវ។ យើងខ្ញុំគ្មានអ្វីដែលត្រូវរាយការណ៍ពីបញ្ហានេះទៀតឡើយ។

**ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសធុនតូច និងមធ្យម និងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលក្រុមហ៊ុនយល់ថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

Crowe

## របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
(លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៩០៩)

### ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវមានការទទួលខុសត្រូវរាល់សកម្មភាពរបស់ក្រុមហ៊ុនដែលធានាអះអាងថា អាចមានលទ្ធិភាពបន្តក្នុងរយៈពេល១២ខែខាងមុខ និងរាល់បញ្ហាដែលមានជាប់ពាក់ព័ន្ធជាមួយនឹងលទ្ធិភាពអាចបន្តរបស់ក្រុមហ៊ុន និងគោលបំណងដែលអាចធ្វើឲ្យមានសកម្មភាពនេះកើតឡើង ដែលតម្រូវឲ្យធ្វើការបង្ហាញទៅជាសាធារណៈដោយសារតែវាមានភាពចាំបាច់។ លើកលែងតែក្រុមប្រឹក្សាភិបាលណាមួយមានបំណងចង់ទូទាត់បំណុលរបស់ក្រុមហ៊ុនទាំងស្រុង ឬក៏អះអាងថានឹងបិទក្រុមហ៊ុន ហើយបើគ្មានសកម្មភាពណាមួយលេចឡើងនោះទេ យើងនៅតែត្រូវការរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដដែល។

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល នឹងមិនមានកំហុសឆ្គងជាសារវន្ត មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំឡើយ។ ហើយធ្វើការរាយការណ៍របាយការណ៍សវនករដែលរាប់បញ្ចូលទាំងមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែមិនមែនធានាអះអាងថាសវនកម្មដែលធ្វើឡើងស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា តែងតែរកឃើញរាល់កំហុសជាសារវន្តនោះឡើយ។ ការបំភាន់អាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានគេចាត់ទុកថាជាសារវន្ត ប្រសិនបើជាលក្ខណៈបុគ្គលឬជាក្រុម ពួកវាអាចជះឥទ្ធិពលដល់ការសម្រេចចិត្តខាងសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដែលផ្អែកលើមូលដ្ឋាននៃ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការសង្ស័យដែលមានជំនាញវិជ្ជាជីវៈនៅសវនកម្មទាំងមូល។ យើងក៏:-

ក). កំណត់ និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវ ខាងសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនថាដោយសារការក្លែងបន្លំ ឬកំហុស។ រៀបចំ និងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបានភស្តុតាងសវនកម្ម ដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើង។ ហានិភ័យដែលមិនរកឃើញកំហុសខាងសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានភាពខ្ពស់ជាង បណ្តាលមកពីកំហុសឆ្គង ព្រោះការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការកែច្នៃ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬការបំពានក្នុងការគ្រប់គ្រងផ្ទៃក្នុង។

Crowe

## របាយការណ៍របស់សវនករឯករាជ្យសម្រាប់សមាជិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
(លេខចុះបញ្ជីក្រុមហ៊ុនៈ ០០០៤៣៩០៩)

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ (តពីទំព័រមុន)

ខ). ទទួលបានការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងសវនកម្មដើម្បីរៀបចំនីតិវិធីសវនកម្ម ដែលសមស្របក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

គ). វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលពាក់ព័ន្ធដែលធ្វើឡើងដោយអ្នកគ្រប់គ្រង។

ឃ). សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់ របស់ក្រុមប្រឹក្សាភិបាលនៃមូលដ្ឋានដែលគួរឱ្យព្រួយបារម្ភនៃគណនេយ្យ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនច្បាស់លាស់នៃសារវន្តមានទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តភាពអាជីវកម្ម។ ប្រសិនបើយើងសន្និដ្ឋានថាមានភាពមិនច្បាស់លាស់នៃសារវន្តយើងខ្ញុំចាំបាច់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់សវនកររបស់យើង ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុ ឬបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិយោបល់សវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើង។ ទោះយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តភាពអាជីវកម្ម។

ង). វាយតម្លៃការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានការលាតត្រដាង និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលតំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍មូលដ្ឋានក្នុងលក្ខណៈដែលទទួលបានការបង្ហាញដោយត្រឹមត្រូវ។

យើងបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីបញ្ហាផ្សេងៗ វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតក្នុងការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើង។

Crowe

**របាយការណ៍របស់សវនករឯករាជ្យសំរាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុន: 00043909)

**បញ្ហាផ្សេងទៀត**

ការធ្វើសវនកម្មរបស់យើងខ្ញុំគឺក្នុងគោលបំណងបង្ហាញពីទស្សនៈទៅលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងមូលជារូបិយប័ណ្ណ ដុល្លារអាមេរិក។ ការបំលែងរបាយការណ៍ហិរញ្ញវត្ថុពីដុល្លារអាមេរិកទៅជាខ្មែររៀលដោយប្រើអត្រាបិទនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១ បានបង្ហាញឡើងក្នុងគោលបំណងវិភាគបន្ថែមហើយមិនមែនជាផ្នែកសំខាន់នៃមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុនោះទេ។ ការបំលែងនេះមិនត្រូវបានធ្វើសវនកម្មទៅតាមនីតិវិធីដែលបានអនុវត្តទៅលើរបាយការណ៍ហិរញ្ញវត្ថុនោះទេ ហេតុដូច្នេះយើងខ្ញុំមិនបានបញ្ចេញទស្សនៈណាមួយទៅលើការបំលែងនេះឡើយ។

**Crowe (KH) Co., Ltd.**
ក្រុមហ៊ុនស្នងការគណនេយ្យករជំនាញ

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ក្រូវ (ខេអេច) ឯ.ក
CROWE (KH) CO. LTD.
KINGDOM OF CAMBODIA

**Onn Kien Hoe**
អភិបាល
ថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២២

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៩០៩

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | កំណត់សម្គាល់ | ២០២១<br>ដុល្លារអាមេរិក | ២០២០<br>ដុល្លារអាមេរិក | ២០២១<br>ខ្មែរពាន់រៀល | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 31,842 | 9,203 | 129,724 | 37,226 |
| សមតុល្យនៅធនាគារនានា | 6 | 96,943 | 61,196 | 394,946 | 247,538 |
| ឥណទាន និងបុរេប្រទាន | 7 | 1,388,974 | 1,532,654 | 5,658,680 | 6,199,585 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 34,203 | 42,293 | 139,343 | 171,075 |
| ប្រាក់តម្កល់តាមច្បាប់ នៅធនាគារជាតិ នៃ កម្ពុជា | 9 | 100,000 | 100,000 | 407,400 | 404,500 |
| គ្រឿងបរិក្ខារ | 10 | 46,344 | 67,291 | 188,805 | 272,192 |
| ទ្រព្យអរូបី | 11 | 50,818 | 67,472 | 207,033 | 272,924 |
| **ទ្រព្យសកម្មសរុប** | | 1,749,124 | 1,880,109 | 7,125,931 | 7,605,041 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| កម្ចី | 12 | 300,000 | 200,000 | 1,222,200 | 809,000 |
| ទ្រព្យអកម្មផ្សេងៗ | 13 | 31,775 | 26,369 | 129,450 | 106,663 |
| **បំណុលសរុប** | | 331,775 | 226,369 | 1,351,650 | 915,663 |
| **មូលធន** | | | | | |
| ដើមទុន | 14 | 2,000,000 | 2,000,000 | 8,000,000 | 8,000,000 |
| ទុនបម្រុងបទប្បញ្ញត្តិ | 15 | 5,572 | 5,657 | 22,536 | 22,882 |
| ខាតបង្គរ | | (588,223) | (351,917) | (2,384,797) | (1,423,504) |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | 136,542 | 90,000 |
| **មូលធនសរុប** | | 1,417,349 | 1,653,740 | 5,774,281 | 6,689,378 |
| **បំណុល និងមូលធនសរុប** | | 1,749,124 | 1,880,109 | 7,125,931 | 7,605,041 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៩០៩

### របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | កំណត់សម្គាល់ | ២០២១<br>ដុល្លារអាមេរិក | ២០២០<br>ដុល្លារអាមេរិក | ២០២១<br>ខ្មែរពាន់រៀល | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 16 | 160,948 | 161,570 | 654,736 | 653,551 |
| ចំណាយការប្រាក់ | 17 | (16,229) | (3,451) | (66,020) | (13,959) |
| **ចំណេញដុល** | | 144,719 | 158,119 | 588,716 | 639,591 |
| ចំណូលផ្សេងៗ | 18 | 40 | 10,002 | 163 | 40,458 |
| ចំណាយលើប្រាក់ខែបុគ្គលិក | 19 | (249,234) | (303,892) | (1,013,884) | (1,229,243) |
| រំលស់លើទ្រព្យរូបី | 10 | (21,136) | (21,082) | (85,981) | (85,277) |
| រំលស់លើទ្រព្យអរូបី | 11 | (16,654) | (15,208) | (67,748) | (61,516) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | 20 | (92,985) | (162,822) | (378,263) | (658,615) |
| សំវិធានធន<br>សម្រាប់ឥណទានបាត់បង់ | 7 | 471 | (9,767) | 1,916 | (39,508) |
| ខាត/ ចំណេញមុនបង់ពន្ធ | | (234,779) | (344,650) | (955,082) | (1,394,109) |
| ចំណាយពន្ធលើប្រាក់ចំនេញ | 21 | (1,612) | (1,610) | (6,558) | (6,512) |
| ខាតបន្ទាប់ពីបង់ពន្ធ | | (236,391) | (346,260) | (961,639) | (1,400,622) |
| ប្រាក់ចំណូលផ្សេងទៀត | | - | - | - | - |
| ខាតក្នុងឆ្នាំ | | (236,391) | (346,260) | (961,639) | (1,400,622) |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០៤៣៨០៩

### របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | កំណត់សម្គាល់ | មូលធន<br>ដុល្លារអាមេរិក | ទុនបម្រុងបទប្បញ្ញត្តិ<br>ដុល្លារអាមេរិក | ខាតបង្គរ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | | 2,000,000 | - | - | 2,000,000 |
| ខាតសុទ្ធសម្រាប់ការិយបរច្ឆេទ | | - | - | (346,260) | (346,260) |
| ផ្ទេរ | | - | 5,657 | (5,657) | - |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០/០១ . ០១.២០២១ | | 2,000,000 | 5,657 | (351,917) | 1,653,740 |
| ខាតសុទ្ធសម្រាប់ការិយបរច្ឆេទ | | - | - | (236,391) | (236,391) |
| ផ្ទេរ | | - | (85) | 85 | - |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | 2,000,000 | 5,572 | (588,223) | 1,417,349 |

| | កំណត់សម្គាល់ | មូលធន<br>ខ្មែរពាន់រៀល | ទុនបម្រុងបទប្បញ្ញត្តិ<br>ខ្មែរពាន់រៀល | ខាតបង្គរ<br>ខ្មែរពាន់រៀល | ទឹកប្រាក់លំអៀងបង្គរពីការប្តូរប្រាក់<br>ខ្មែរពាន់រៀល | សរុប<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|---|
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ ២០២០ | | 8,000,000 | - | - | - | 8,000,000 |
| ខាតសុទ្ធសម្រាប់ការិយបរច្ឆេទ | | - | - | (1,400,622) | - | (1,400,622) |
| ផ្ទេរ | | - | 22,882 | (22,882) | - | - |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | - | 90,000 | 90,000 |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០/០១ .០១.២០២១ | | 8,000,000 | 22,882 | (1,423,504) | 90,000 | 6,689,378 |
| ខាតសុទ្ធសម្រាប់ការិយបរច្ឆេទ | | | | (961,639) | - | (961,639) |
| ផ្ទេរ | | - | (346) | 346 | - | - |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | - | 46,542 | 46,542 |
| | | 8,000,000 | 22,536 | (2,384,797) | 136,542 | 5,774,281 |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)

លេខ**ចុះបញ្ជី**ក្រុមហ៊ុន: ០០០៥៣៩០៩

**របាយការណ៍បម្រែបម្រួលសាច់ប្រាក់**

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | កំណត់សម្គាល់ | ២០២១<br>ដុល្លារអាមេរិក | ២០២០<br>ដុល្លារអាមេរិក | ២០២១<br>ខ្មែរពាន់រៀល | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ខាតមុនបង់ពន្ធប្រាក់ចំណេញ | | (234,779) | (344,650) | (955,082) | (1,394,109) |
| និយ័តភាព៖ | | | | | |
| សំវិធានធនសម្រាប់ឥណទានបាត់បង់ | 7 | (471) | 9,767 | (1,916) | 39,508 |
| រំលស់លើគ្រឿងបរិក្ខារ | 10 | 21,136 | 21,082 | 85,981 | 85,277 |
| រំលស់លើទ្រព្យអរូបី | 11 | 16,654 | 15,208 | 67,748 | 61,516 |
| ចំណាយការប្រាក់ | | 16,229 | 3,451 | 66,020 | 13,959 |
| ខាតមុនបម្រែបម្រួលទុនបង្វិល | | (181,231) | (295,142) | (737,249) | (1,193,849) |
| ការកើនឡើងនិងការថយចុះនៃ៖ | | | | | |
| - ឥណទាននិងបុរេប្រទាន | 7 | 144,151 | (1,542,421) | 587,271 | (6,239,093) |
| - ទ្រព្យសកម្មផ្សេង | 8 | 8,089 | (42,293) | 32,955 | (171,075) |
| - ប្រាក់បញ្ញើតាមច្បាប់ | 9 | - | (100,000) | - | (404,500) |
| - បំណុលផ្សេងៗ | 13 | 5,406 | 26,369 | 22,024 | 106,663 |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុងសកម្មភាព ប្រតិបត្តិការ** | | (23,585) | (1,953,487) | (94,999) | (7,901,854) |
| ពន្ធប្រាក់ចំណេញដែលត្រូវបង់ | | (1,612) | (1,610) | (6,558) | (6,512) |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុងសកម្មភាពប្រតិបត្តិការសុទ្ធ** | | (25,197) | (1,955,097) | (101,557) | (7,908,366) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញគ្រឿងបរិក្ខារ | 10 | (188) | (88,373) | (765) | (357,467) |
| ការទិញទ្រព្យអរូបី | 11 | - | (82,680) | - | (334,444) |
| **សាច់ប្រាក់សុទ្ធដែលត្រូវបានក្នុងសកម្មភាពវិនិយោគ** | | (188) | (171,053) | (765) | (691,911) |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩)
លេខ**ចុះបញ្ជី**ក្រុមហ៊ុន: ០០០៨៣៩០៩

## របាយការណ៍បម្រែបម្រួលសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

| | | | | | |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់សម្រាប់សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការថយចុះនៃសាច់ប្រាក់សុទ្ធ | 12 | 100,000 | 200,000 | 407,400 | 809,000 |
| ការប្រាក់បានបង់ | | (16,229) | (3,451) | (66,020) | (13,959) |
| ចំណូលពីការចេញភាគហ៊ុនធម្មតា | 14 | - | 2,000,000 | - | 8,000,000 |
| **ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញវត្ថុ** | | 83,771 | 2,196,549 | 341,380 | 8,795,041 |
| ការថយចុះនៃសាច់ប្រាក់សុទ្ធ | | 58,836 | 70,399 | 239,058 | 194,764 |
| សាច់ប្រាក់នៅដើមការិយបរិច្ឆេទក្នុងឆ្នាំ | | 70,399 | - | 284,764 | - |
| បម្រែបម្រួលអត្រាប្តូរប្រាក់ | | - | - | 848 | 90,000 |
| សាច់ប្រាក់ចុងគ្រា | | 128,785 | 70,399 | 524,670 | 284,764 |

### សាច់ប្រាក់និងសមមូលសាច់ប្រាក់មានដូចខាងក្រោម:

| | កំណត់សម្គាល់ | ២០២១<br>ដុល្លារអាមេរិក | ២០២០<br>ដុល្លារអាមេរិក | ២០២១<br>ខ្មែរពាន់រៀល | ២០២០<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | 5 | 31,842 | 9,203 | 129,724 | 37,226 |
| សមតុល្យនៅធនាគារនានា | 6 | 96,943 | 61,196 | 394,946 | 247,538 |
| សាច់ប្រាក់សុទ្ធ និងសាច់ប្រាក់សមមូលសរុប | | 128,785 | 70,399 | 524,670 | 284,764 |

## សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាភិបាល

យើងខ្ញុំជាថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក** សូមប្រកាសថា តាមយោបល់របស់យើងខ្ញុំ ព័ត៌មានហិរញ្ញវត្ថុបន្ថែមដែលមានភ្ជាប់នៅទំព័របន្ទាប់រួមមានព័ត៌មានតម្រូវដោយ ប្រកាសនានា នៃ ធនាគារជាតិនៃកម្ពុជា ត្រូវបានរៀបចំឡើងដើម្បីបង្ហាញនូវទិដ្ឋភាពពិតនៃព័ត៌មានហិរញ្ញវត្ថុ របស់ក្រុមហ៊ុន នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២១។ ព័ត៌មាន និងទិន្នន័យដូចមាននៅទំព័របន្ទាប់ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំក្រុមហ៊ុន។

G B MICROFINANCE INSTITUTION PLC.
KINGDOM OF CAMBODIA

លោក តាំង គួងហាវ
ប្រធានក្រុមប្រឹក្សាភិបាល
ថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២២

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក
## ឧបសម្ព័ន្ធ ៖ ព័ត៌មានហិរញ្ញវត្ថុបន្ថែម និងកំណត់សំគាល់ដែលតំរូវដោយធនាគារជាតិ នៃ កម្ពុជា សម្រាប់ការិយបរិច្ឆេទចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

### មូលនិធិផ្ទាល់សុទ្ធ

អនុលោមទៅតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជាលេខ ធ.៧-៧០០៤៧ ចុះ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ កែតម្រូវ ដោយប្រកាសលេខ ធ.៧-០៧-១៣២ ចុះ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ក្រុមហ៊ុនត្រូវរក្សា មូលនិធិផ្ទាល់ សុទ្ធយ៉ាងតិចបំផុតស្មើនឹងដើមទុនដែលបានបង់។ មូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ មានតួលេខដូចខាងក្រោម ៖

| | ២០២១<br>ដុល្លារអាមេរិក | ២០២១<br>ខ្មែរពាន់រៀល |
|---|---|---|
| **ខ្ទង់ត្រូវបូក "ក"** | | |
| ដើមទុន | 2,000,000 | 8,000,000 |
| ទុនបំរុងដោយឡែកពីទុនបំរុងលើការវាយតម្លៃឡើងវិញ | - | - |
| បុព្វលាភភាគហ៊ុន | - | - |
| សំវិធានធនចំពោះហានិភ័យទូទៅនៃប្រតិបត្តិការធនាគារ | - | - |
| ចំណេញរក្សាទុកសម្រាប់វិនិយោគបន្ត | - | - |
| លទ្ធផលចំណេញនៃការិយបរិច្ឆេទ | (588,223) | (2,384,797) |
| ភាគលាភ | - | - |
| ខ្ទង់ផ្សេងៗទៀតដែលអនុញ្ញាតដោយធនាគារជាតិ នៃ កម្ពុជា | - | - |
| **សរុបខ្ទង់ត្រូវបូក "ក"** | 1,411,777 | 5,615,203 |
| **ខ្ទង់ត្រូវដក "ខ"** | | |
| សម្រាប់ភាគទុនិក អភិបាល អ្នកគ្រប់គ្រង | 17,420 | 70,967 |
| • ដើមទុនមិនទាន់បង់ | - | - |
| • ឥណទាន កម្ចី | - | - |
| កាន់ភាគហ៊ុនផ្ទាល់នៅតម្លៃសៀវភៅរបស់ពួកគេ | - | - |
| ខាតបង្គរ | - | - |
| ចំណាយលើការបង្កើតក្រុមហ៊ុន | - | - |
| ខាតដែលកំណត់តាមគ្រាក្រៅពីការខាតនាចុងការិយបរិច្ឆេទ | - | - |
| **សរុបខ្ទង់ត្រូវដក "ខ"** | 17,420 | 70,967 |
| **គ. មូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន (ក-ខ)** | 1,394,357 | 5,544,236 |
| **ខ្ទង់ត្រូវបូក "ឃ"** | | |
| ទុនបម្រុងពីការវាយតម្លៃឡើងវិញ | - | - |
| អនុបំណុល | - | - |
| ខ្ទង់ផ្សេងៗទៀតដែលអនុញ្ញាតដោយធនាគារជាតិ នៃ កម្ពុជា | - | - |
| **សរុបខ្ទង់ត្រូវបូក "ឃ"** | - | - |
| **ខ្ទង់ត្រូវដក "ង"** | | |
| ភាគកម្មមូលនិធិក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនានា | - | - |
| ខ្ទង់ផ្សេងៗ | - | - |
| **សរុបខ្ទង់ត្រូវដក "ង"** | - | - |
| **ច. មូលនិធិផ្ទាល់សុទ្ធ (គ+ឃ-ង)** | 1,394,357 | 5,544,236 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី មក
## ឧបសម្ព័ន្ធ ៖ ព័ត៌មានហិរញ្ញវត្ថុបន្ថែម និងកំណត់សំគាល់ដែលតំរូវដោយធនាគារជាតិ នៃ កម្ពុជា សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

### អនុបាតសាច់ប្រាក់ងាយស្រួល

អនុលោមទៅតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជាលេខ ធ.៧-០០-១៩៨ ចុះ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណគប្បីរក្សាអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងហោចណាស់ ១០០%គ្រប់ពេលវេលា ។ គិតត្រឹមថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២១ អនុបាតសាច់ប្រាក់ងាយស្រួលរបស់ក្រុមហ៊ុនពុំមានសមតុល្យទេដោយសារតែមិនមាន សមតុល្យសន្សំ ដោយស្មគ្រ័ចិត្ត។

| | ២០២១<br>ដុល្លារអាមេរិក | ២០២១<br>ខ្មែរពាន់រៀល |
|---|---|---|
| **I. ភាគយកនៃអនុបាត: ទ្រព្យសកម្មសន្ទនីយ** | | |
| ១. សមតុល្យធនាគារ | | |
| - ធាតុឥណពន្ធ | | |
| សាច់ប្រាក់ក្នុងដៃ | 31,842 | 129,724 |
| ប្រាក់បញ្ញើនៅធនាគារជាតិ នៃ កម្ពុជា (មិនរួមបញ្ចូលប្រាក់បញ្ញើតម្រូវតាមច្បាប់ និងទុនបម្រុង) | - | - |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ | 96,943 | 394,946 |
| សមតុល្យនៅភ្នាក់ងារផ្សេងៗ | - | - |
| ប្រាក់កម្ចីផ្តល់ដល់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុដែលមានរយៈពេលនៅសល់ មិនលើសពី១ខែ | - | - |
| ប្រាក់កម្ចីផ្តល់ដល់អតិថិជនដែលមានរយៈពេលនៅសល់មិនលើសពី១ខែ | - | - |
| | 128,785 | 524,670 |
| **ដក:** | | |
| - ធាតុឥណទាន | | |
| សមតុល្យឥណទានជាមួយធនគារជាតិ នៃ កម្ពុជា ធនាគារ ឬ គ្រឹះស្ថានហិរញ្ញវត្ថុ | - | - |
| កម្ចីពីធនាការជាតិ នៃ កម្ពុជា និងធនាគារដែលមានរយៈពេលនៅសល់ មិនលើសពី១ខែ | - | - |
| **សាច់ប្រាក់ងាយស្រួលសុទ្ធ** | - | - |
| ២. កម្ចីមានអាយុមិនលើសពី១ខែ(មិនបញ្ចូលលកម្ចីដែលគ្មានកាលកំណត់) | - | - |
| ៣. ប័ណ្ណរតនាគារមានអាយុមិនលើសពី១ខែ | - | - |
| **ភាគយកសរុប (ក)** | 128,785 | 524,670 |
| **II. ភាគបែង-ចំនួនប្រាក់បញ្ញើរដែលបានកែរសម្រួល (ខ)** | | |
| ប្រាក់សន្សំដោយស្មគ្រ័ចិត្ត ២៥% | - | - |
| **III. អនុបាតសាច់ប្រាក់ងាយស្រួល (ក/ខ)** | មិនមាន | |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក
## ឧបសម្ព័ន្ធ ៖ ព័ត៌មានហិរញ្ញវត្ថុបន្ថែម និងកំណត់សំគាល់ដែលតំរូវដោយធនាគារជាតិ នៃ កម្ពុជា សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

### ចំណាត់ថ្នាក់ឥណទាននិងសំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ និងបាត់បង់

| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | ឥណទានដុល<br>ដុល្លារអាមេរិក | សំវិធានធន<br>% | បទដ្ឋានរបស់<br>ធនាគារជាតិ<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| ១. ឥណទានអាយុក្រោម១ឆ្នាំ | | | | |
| ស្តង់ដារ | | - | 1% | - |
| ឃ្លាំមើល | | - | 3% | - |
| ក្រោមស្តង់ដារ | | - | 20% | - |
| ជាប់សង្ស័យ | | - | 50% | - |
| បាត់បង់ | | - | 100% | - |
| | **ក** | - | | - |

| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | ឥណទានដុល<br>ដុល្លារអាមេរិក | សំវិធានធន<br>% | បទដ្ឋានរបស់<br>ធនាគារជាតិ<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| ២. ឥណទានអាយុលើស១ឆ្នាំ | | | | |
| ស្តង់ដារ | | 1,349,326 | 1% | 13,493 |
| ឃ្លាំមើល | | 48,944 | 3% | 1,468 |
| ក្រោមស្តង់ដារ | | - | 20% | - |
| ជាប់សង្ស័យ | | - | 50% | - |
| បាត់បង់ | | - | 100% | - |
| | **ខ** | 1,398,270 | | 14,962 |
| សរុបរួម | **ក+ខ** | 1,398,270 | | 14,962 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជី ប៊ី ម.ក

## ឧបសម្ព័ន្ធ ៖ ព័ត៌មានហិរញ្ញវត្ថុបន្ថែម និងកំណត់សំគាល់ដែលតំរូវដោយធនាគារជាតិ នៃ កម្ពុជា សម្រាប់ការិយបរិច្ឆេទចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

### ការគណនាស្ថានភាពចំហាសុទ្ធនៃរូបិយប័ណ្ណ

អនុលោមទៅតាមលិខិតរបស់ធនាគារជាតិ នៃកម្ពុជាលេខ ធ៧. ០២០. ៨៦៨ ឆ.ត ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវរក្សាទុកគណនេយ្យកម្មប្រតិបត្តិការរូបិយប័ណ្ណបរទេស នៃមូលនិធិផ្ទាល់សុទ្ធរបស់ ក្រុមហ៊ុនដូចតទៅ៖

| រូបិយប័ណ្ណ | ខ្ទង់ផ្សេងៗទៀតបន្ទាប់ពីដកចេញសំវិធានធន | | ស្ថានភាពរូបិយប័ណ្ណចំហាសុទ្ធ | រូបិយប័ណ្ណចំហាសុទ្ធ/ មូលនិធិផ្ទាល់សុទ្ធ (%) | កំរិតកំណត់ (%) | ភាពលើស (%) |
|---|---|---|---|---|---|---|
| | ១ | ២ | ៥ | | | |
| | ទ្រព្យសកម្ម | ទ្រព្យអកម្មនិងមូលធន | +(វែង) ឬ - (ខ្លី) | | | |
| | + | - | (១+២+៣+៤) | | | |
| ប្រាក់ដុល្លារអាមេរិក | 1,684,985 | (1,748,302) | (63,317) | -3.6% | **20%** | - |

អនុបាតសោធនភាព: 1,394,357

#J-37, Street Lum, Sangkat Tonle Bassac,
Khan Chamkamorn, Phnom Penh City,
Kingdom of Cambodia.

(+855) 23 977 778 | (+855) 99 570 555

info@gbmfi.com.kh

www.gbmfi.com.kh